# ព្រះរាជក្រម

នស/រកម/០៧០៦/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៨១/០០៨/២០០៦ កបធ.ច ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាមួយ.–**

មាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ត្រូវបានកែប្រែដូចខាងក្រោម :

**មាត្រា ១៨ .– ថ្មី**

អគ្គសវនករ និងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

អគ្គសវនករ និងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសម្រាប់អាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយអាចទទួលការតែងតាំងតែមួយដងទៀតប៉ុណ្ណោះ នៅពេលចប់អាណត្តិទី ១ របស់ខ្លួន ។

ក្នុងករណីដែលអគ្គសវនករ ឬ អគ្គសវនកររងទទួលអនិច្ចកម្ម ឬ លាលែង ឬ បាត់បង់សមត្ថភាពពលកម្ម ឬ មានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករ ឬ អគ្គសវ-

1/4

នកររងថ្មីជំនួស តាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។

**មាត្រា ៣៖**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/ល.០៦០៤.០៣៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៣៥៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ហ៊ុន ជិនកេន**